**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ: ២៥២/២៣ ក.ប/ប្រ.ក.ប.ស.ស

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល សម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី ក្រសួងសុខាភិបាល**

**រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៦ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរំលូតកូន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- បានឃើញអនុក្រឹត្យលេខ១៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកែប្រែនិងដំឡើងប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសពមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលទទួលមរណភាព
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភជូនសមាជិក **ប.ស.ស**. ជាស្ត្រីមានផ្ទៃពោះ ជាពិសេសកម្មការិនី និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ ដើម្បីចូលរួមលើកកម្ពស់សុខុមាលភាពមាតា និងទារក រួមចំណែកដោះស្រាយកង្វះអាហារូបត្ថម្ភ ព្រមទាំងជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសមាជិក **ប.ស.ស**. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ ដូចខាងក្រោម៖

- កម្មករនិយោជិតជាស្ត្រី ជាក្រុមគោលដៅនៃកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងមានសញ្ជាតិខ្មែរ
- មន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានការទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈ។

បុគ្គលដទៃទៀត ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**ប្រការ៣.-**

វាក្យសព្ទបច្ចេកទេស ដែលប្រើនៅក្នុងប្រកាសអន្តរក្រសួងនេះ មាននិយមន័យដូចខាងក្រោម៖

| | |
|---|---|
| - អ្នកតំណាងស្របច្បាប់ | សំដៅដល់ប្តីឬអាណាព្យាបាលរបស់សាមីខ្លួនដែលទទួលស្គាល់ដោយបេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**)។ |
| - ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល | សំដៅដល់កម្មវិធីឧបត្ថម្ភសាច់ប្រាក់មុន និងក្រោយពេលសម្រាលពេលសម្រាលដែលគាំទ្រដោយថវិការដ្ឋ។ |
| - មូលដ្ឋានសុខាភិបាលសាធារណៈ | សំដៅដល់អង្គភាពសុខាភិបាលសាធារណៈដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.**។ |

## ជំពូកទី២
## ប្រតិបត្តិករបើកផ្តល់

**ប្រការ៤.-**

**ប.ស.ស.** ជាប្រតិបត្តិករបើកផ្តល់ប្រាក់ឧបត្ថម្ភក្រោមកម្មវិធីប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក **ប.ស.ស.** ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ ដូចមានកំណត់ក្នុងប្រការ២ នៃប្រកាសនេះ។

## ជំពូកទី៣
## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តកម្មវិធី
## ផ្នែកទី១
## លក្ខខណ្ឌ

**ប្រការ៥.-**

សមាជិក **ប.ស.ស.** ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ មានសិទ្ធិចុះឈ្មោះដើម្បីទទួលប្រាក់ឧបត្ថម្ភលុះត្រាតែ៖

- មានបណ្ណសមាជិក **ប.ស.ស.** និងមានសុពលភាពប្រើប្រាស់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ
- បានទៅទទួលសេវាសុខភាពនៅមូលដ្ឋានសុខាភិបាលសាធារណៈតាមតារាងកម្មវិធីដែលសាមីខ្លួនទទួលបានប្រាក់ឧបត្ថម្ភដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ ដោយមានភ្ជាប់មកជាមួយនូវសៀវភៅសុខភាពមាតាដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ
- កុមារដែលម្តាយបានចុះឈ្មោះរួចក្នុងកម្មវិធី កុមារនោះត្រូវចូលក្នុងកម្មវិធីដោយស្វ័យប្រវត្តិ ដោយត្រូវភ្ជាប់មកជាមួយនូវបណ្ណសុខភាពកុមារ។

# ផ្នែកទី២
# បែបបទ និងនីតិវិធី

**ប្រការ៦.-**

សមាជិក **ប.ស.ស.** ជាស្ត្រីត្រូវបំពេញទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភលើកទី១ សម្រាប់ដំណាក់កាលមុនពេលសម្រាល ដោយត្រូវភ្ជាប់មកជាមួយនូវ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បណ្ណសមាជិក **ប.ស.ស.**
- លេខទូរសព្ទ និងលេខគណនីធនាគារដែលកំណត់ដោយ **ប.ស.ស.**
- សៀវភៅសុខភាពមាតាបញ្ជាក់ពីអាយុគភ៌ដំបូងដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ។

សមាជិក **ប.ស.ស.** ជាស្ត្រីត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទី២ លើកទី៣ តាមរយៈកម្មវិធីលើទូរសព្ទដៃឈ្មោះ "ភ្នាក់ងារ **ប.ស.ស.** (NSSF Agent App)" ។

សមាជិក **ប.ស.ស.** ជាស្ត្រីត្រូវបំពេញទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភលើកទី៤ បន្ទាប់ពីបានពិនិត្យផ្ទៃពោះរួច ដោយត្រូវភ្ជាប់មកជាមួយនូវ៖

- បណ្ណសមាជិក **ប.ស.ស.**
- សៀវភៅសុខភាពមាតាបញ្ជាក់ពីអាយុ៣៦(សាមសិបប្រាំមួយ) ទៅ៣៨(សាមសិបប្រាំបី)សប្តាហ៍របស់គភ៌ដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ។

**ប្រការ៧.-**

សមាជិក **ប.ស.ស.** ត្រូវស្នើសុំប្រាក់ឧបត្ថម្ភសម្រាប់ពេលសម្រាលកូន ដោយបំពេញទម្រង់ "ស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន" ដែលកំណត់ដោយអគ្គនាយក **ប.ស.ស.**។ ការស្នើសុំប្រាក់ឧបត្ថម្ភពេលសម្រាលកូន ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត។

**ប្រការ៨.-**

សមាជិក **ប.ស.ស.** ជាស្ត្រីត្រូវទទួលបានប្រាក់ឧបត្ថម្ភក្រោយពេលសម្រាល តាមរយៈកម្មវិធីលើទូរសព្ទដៃឈ្មោះ "ភ្នាក់ងារ **ប.ស.ស.** (NSSF Agent App)" ។

សមាជិក **ប.ស.ស.** ត្រូវទទួលបានប្រាក់ឧបត្ថម្ភ នៅពេលយកកូនមកទទួលថ្នាំបង្ការសុខភាពនៅមូលដ្ឋានសុខាភិបាលសាធារណៈ តាមរយៈកម្មវិធីលើទូរសព្ទដៃឈ្មោះ "ភ្នាក់ងារ **ប.ស.ស.** (NSSF Agent App)" ។

**ប្រការ៩.-**

សមាជិក **ប.ស.ស.** ជាស្ត្រីត្រូវទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ករណីរលូតកូន ដូចមានកំណត់ក្នុងប្រការ១១ នៃប្រកាសអន្តរក្រសួងនេះ ត្រូវបំពេញទម្រង់ស្នើសុំដោយភ្ជាប់មកជាមួយនូវ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បណ្ណសមាជិក **ប.ស.ស.**
- លេខទូរសព្ទ និងលេខគណនីធនាគារដែលកំណត់ដោយ **ប.ស.ស.**
- លិខិតបញ្ជាក់រលូតកូនដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ។



4

ក្នុងករណីម្ដាយស្លាប់នៅពេលសម្រាល ឬកូនស្លាប់ពេលសម្រាល និងក្រោយពេលសម្រាល ប្ដី ឬអ្នកតំណាងស្របច្បាប់ត្រូវបំពេញទម្រង់ "ស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន" ដោយភ្ជាប់នូវសេចក្ដីចម្លងសំបុត្រមរណភាពរបស់ម្ដាយ ឬលិខិតបញ្ជាក់មរណភាពរបស់កូនដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ។

## ផ្នែកទី៣
## ការផ្ដល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

**ប្រការ១០ ._**

ប្រាក់ឧបត្ថម្ភត្រូវផ្ដល់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ ដែលមកទទួលសេវាពិនិត្យសុខភាពនៅមូលដ្ឋានសុខាភិបាលសាធារណៈ ជាដំណាក់កាលដូចខាងក្រោម៖

ដំណាក់កាលទី១ ផ្ដល់ការឧបត្ថម្ភចំនួន ៨០ ០០០ (ប្រាំបីម៉ឺន)រៀល ក្នុង ១(មួយ)លើក សម្រាប់ការមកទទួលសេវាពិនិត្យផ្ទៃពោះ ដែលផ្ដល់ជាអតិបរមាចំនួន ៤(បួន)លើក មុនពេលសម្រាលកូន។

ដំណាក់កាលទី២ ផ្ដល់ការឧបត្ថម្ភនៅពេលសម្រាលកូន តាមការកំណត់ដូចខាងក្រោម៖

- សម្រាលកូនទោល (មួយ) ទទួលបាន ៨០០ ០០០ (ប្រាំបីសែន)រៀល
- សម្រាលកូនភ្លោះ (ពីរ) ទទួលបាន ១ ២០០ ០០០ (មួយលានពីរសែន)រៀល
- សម្រាលកូនភ្លោះ (បី) ទទួលបាន ១ ៦០០ ០០០ (មួយលានប្រាំមួយសែន)រៀល។

ដំណាក់កាលទី៣ ផ្ដល់ការឧបត្ថម្ភចំនួន ៨០ ០០០ (ប្រាំបីម៉ឺន)រៀល ក្នុង ១(មួយ)លើក ដែលផ្ដល់ជាអតិបរមាចំនួន ១០(ដប់)លើក ក្នុងនោះ ៣(បី)លើក នៅពេលមកទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាលកូន និង ៧(ប្រាំពីរ)លើក នៅពេលយកកូនមកទទួលថ្នាំបង្ការរហូតដល់អាយុ ២(ពីរ)ឆ្នាំ។

ករណីកូនភ្លោះ ចំនួនប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវផ្ដល់ជូនតាមចំនួនកូនជាក់ស្ដែង។

**ប្រការ១១ ._**

ករណីរលូតកូន ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ត្រូវផ្ដល់ជូនតាមការកំណត់ដូចខាងក្រោម៖

- ៨០ ០០០ (ប្រាំបីម៉ឺន)រៀល ចំនួន ១(មួយ)លើក ករណីគភ៌មានអាយុក្រោម ១២(ដប់ពីរ)សប្ដាហ៍
- ៨០ ០០០ (ប្រាំបីម៉ឺន)រៀល ចំនួន ១(មួយ)លើក និងផ្ដល់ជូនជាអតិបរមាមានចំនួន ២(ពីរ)លើក ករណីគភ៌អាយុពី ១២(ដប់ពីរ)សប្ដាហ៍ ដល់ ២៤(ម្ភៃបួន)សប្ដាហ៍ ដោយលើកទី២ ផ្ដល់ជូនសម្រាប់ការមកពិនិត្យសុខភាពក្រោយរលូត។

ក្នុងករណីរំលូត ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលមិនត្រូវបានផ្ដល់ជូនឡើយ និងអ្នកទទួលផលត្រូវចាកចេញពីកម្មវិធីនេះ លើកលែងតែករណីរំលូតស្របតាមច្បាប់ស្ដីពីការរំលូតកូន។

ករណីកូនស្លាប់ពេលសម្រាល ឬក្រោយពេលសម្រាល ប្រាក់ឧបត្ថម្ភត្រូវបន្តផ្ដល់ជូនដូចខាងក្រោម៖

- សម្រាលកូនទោល (មួយ) ទទួលបាន ៨០០ ០០០ (ប្រាំបីសែន)រៀល
- សម្រាលកូនភ្លោះ (ពីរ) ទទួលបាន ១ ២០០ ០០០ (មួយលានពីរសែន)រៀល
- សម្រាលកូនភ្លោះ (បី) ទទួលបាន ១ ៦០០ ០០០ (មួយលានប្រាំមួយសែន)រៀល

- ផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៨០ ០០០ (ប្រាំបីម៉ឺន)រៀល ក្នុង ១(មួយ)លើក និងផ្តល់ជូនជាអតិបរមា ចំនួន ៣(បី)លើក នៅពេលម្តាយមកទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាល។

ករណីម្តាយស្លាប់នៅពេលសម្រាល ប្រាក់ឧបត្ថម្ភត្រូវបន្តផ្តល់ជូនអ្នកតំណាងស្របច្បាប់ ឬអ្នកដែលនាំកូនមកទទួលសេវា៖

- សម្រាលកូនទោល ទទួលបាន ៨០០ ០០០ (ប្រាំបីសែន)រៀល
- សម្រាលកូនភ្លោះពីរ ទទួលបាន ១ ២០០ ០០០ (មួយលានពីរសែន)រៀល
- សម្រាលកូនភ្លោះបី ទទួលបាន ១ ៦០០ ០០០ (មួយលានប្រាំមួយសែន)រៀល
- ផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៨០ ០០០ (ប្រាំបីម៉ឺន)រៀល ក្នុង ១(មួយ)លើក និងផ្តល់ជូនជាអតិបរមា ចំនួន ១០(ដប់)លើក នៅពេលយកកូនមកទទួលសេវាថែទាំសុខភាពរហូតដល់កូនអាយុ ២(ពីរ) ឆ្នាំ។

## ជំពូកទី៤
## បញ្ញត្តិផ្សេងៗ

**ប្រការ១២ .-**

មន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យា ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះត្រូវទទួលបានប្រាក់ឧបត្ថម្ភមាតុភាពសម្រាប់ការសម្រាលកូនដូចមានចែងក្នុងអនុក្រឹត្យលេខ១៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសពមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលទទួលមរណភាព ជំនួសឱ្យប្រាក់ឧបត្ថម្ភដំណាក់កាលទី២ ក្នុងប្រការ១០ និងវាក្យខណ្ឌទី៣ ក្នុងប្រការ១១ នៃប្រកាសនេះ រហូតមានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

**ប្រការ១៣ .-**

មូលដ្ឋានសុខាភិបាលសាធារណៈ ត្រូវមានភារកិច្ចបញ្ចូលទិន្នន័យការប្រើប្រាស់របស់សមាជិក **ប.ស.ស.** យ៉ាងយូរ៣(បី)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចូលទទួលសេវាពិនិត្យសុខភាពមុន និងក្រោយសម្រាលពេលសម្រាលកូន និងការនាំកូនមកទទួលថ្នាំបង្ការ។

**ប្រការ១៤ .-**

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ ត្រូវចាប់ផ្តើមអនុវត្តពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៣ តទៅ ដោយត្រូវបើកផ្តល់ជាដំណាក់កាលតាមកាលបរិច្ឆេទដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងទី២ នៃប្រកាសនេះ។

## ជំពូកទី៥
## ថវិកាអនុវត្តកម្មវិធី

**ប្រការ១៥.-**

ថវិកាសម្រាប់អនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក **ប.ស.ស.** ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ ត្រូវហិរញ្ញប្បទានដោយថវិការដ្ឋ តាមរយៈមូលនិធិហិរញ្ញប្បទានគាំពារសង្គម (**ម.គ.ស.**)។

ថវិកាសម្រាប់អនុវត្តកម្មវិធីនេះ ត្រូវគ្រោង និងកត់ត្រានៅក្នុងក្របខណ្ឌនៃកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល។

**ប្រការ១៦.-**

ក្រសួងសុខាភិបាល ត្រូវបោះផ្សាយអាណត្តិឧបត្ថម្ភធននូវកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តកម្មវិធីនេះ នៅរៀងរាល់ត្រីមាស ឬតាមតម្រូវការចំណាយជាក់ស្តែង ដើម្បីរក្សាទុកក្នុងគណនីប្រាក់បញ្ញើរបស់ **ម.គ.ស.** នៅធនាគារជាតិនៃកម្ពុជា។

**ប.ស.ស.** ត្រូវរៀបចំស្នើសុំបុរេប្រទានប្រចាំត្រីមាស ឬតាមតម្រូវការចំណាយជាក់ស្តែង ដោយភ្ជាប់មកជាមួយនូវគ្រោងចំណាយលម្អិត តាមរយៈអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (**អ.ក.គ**) ដើម្បីលើកសំណើបុរេប្រទានថវិកាជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ពិនិត្យ និងសម្រេច។

**អ.ក.គ** រៀបចំផ្តល់បុរេប្រទានថវិកាជូន **ប.ស.ស.** តាមរយៈមូលប្បទានបត្រ ឬការផ្ទេរសាច់ប្រាក់ចូលគណនីរបស់ **ប.ស.ស.** បន្ទាប់ពីទទួលបានការពិនិត្យ និងសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ផ្តល់ថវិកាតាមការស្នើសុំ។

**ប្រការ១៧.-**

**ប.ស.ស.** ត្រូវជម្រះចំណាយជាប្រចាំជាមួយ **ម.គ.ស.** ដែលមាន **អ.ក.គ** ជាសេនាធិការ និងធ្វើរបាយការណ៍បិទបញ្ជីចំណូល ចំណាយប្រចាំឆ្នាំ ស្របតាមបទដ្ឋានគតិយុត្តហិរញ្ញវត្ថុជាធរមាន។

## ជំពូកទី៦
## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ប្រការ១៨.-**

ក្រុមប្រឹក្សាជាតិគាំពារសង្គមមានតួនាទីដឹកនាំការតាមដាន ត្រួតពិនិត្យប្រសិទ្ធភាព និងការវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តកម្មវិធីនេះ។

ក្រុមប្រឹក្សាជាតិគាំពារសង្គម មានសិទ្ធិចាត់តាំងមន្ត្រីជំនាញពាក់ព័ន្ធចុះពិនិត្យ និងសង្កេតជាក់ស្តែងដល់ទីកន្លែងអំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនេះ។

**ប្រការ១៩.-**

**ប.ស.ស.** ត្រូវរៀបចំរបាយការណ៍ប្រចាំខែស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះជូន ក្រសួងអាណាព្យាបាល **ប.ស.ស.** ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** និងក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ២០ .-**

ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់សមាជិក **ប.ស.ស**. ជាកម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន ដូចមានចែងក្នុងប្រការ៨ នៃប្រកាសអន្តរក្រសួងលេខ៤៩៧ សហវ.ប្រក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីតម្លៃកញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធម៌សុខាភិបាល ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន និងនីតិវិធីអនុវត្តចំណាយ ត្រូវទុកជានិរាករណ៍។

**ប្រការ២១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២២ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៥កើត ខែ ស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០២៣

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងសុខាភិបាល** | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** |
| **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **ម៉ម ប៊ុនហេង** | **អ៊ិត សំហេង** |

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ២២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ...២៥២/២៣...ក.ប/ប្រ.ក.ប.ស.ស.ចុះថ្ងៃទី...២១...ខែ...សីហា...ឆ្នាំ២០២៣
ស្តីពីការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ
និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ

## តារាងកម្មវិធីដែលសាមីខ្លួនទទួលបានប្រាក់ឧបត្ថម្ភ

| ដំណាក់កាល | ចំនួនលើក | ពេលវេលាទៅពិនិត្យសុខភាព |
|---|---|---|
| ដំណាក់កាលទី១ | ពិនិត្យផ្ទៃពោះលើកទី១ | មានគភ៌អាយុតិចជាង១២សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះលើកទី២ | មានគភ៌អាយុ២០ទៅ២៤សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះលើកទី៣ | មានគភ៌អាយុ៣០ទៅ៣២សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះលើកទី៤ | មានគភ៌អាយុ៣៦ទៅ៣៨សប្តាហ៍ |
| ដំណាក់កាលទី២ | ពេលសម្រាលកូន | តាមភាពជាក់ស្តែង |
| ដំណាក់កាលទី៣ | ពិនិត្យសុខភាពក្រោយសម្រាលលើកទី១<br>(ពិនិត្យទាំងម្តាយ និងកូន) | ថ្ងៃទី៧ក្រោយសម្រាល |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី២<br>(ពិនិត្យទាំងម្តាយ និងកូន) | ថ្ងៃទី១៤ក្រោយសម្រាល |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៣<br>(ពិនិត្យទាំងម្តាយ និងកូន) | កូនមានអាយុ១ខែកន្លះ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៤<br>(ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ២ខែកន្លះ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៥<br>(ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ៣ខែកន្លះ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៦<br>(ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ៦ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៧<br>(ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ៩ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៨<br>(ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ១២ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៩<br>(ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ១៨ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី១០<br>(ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ២៤ខែ |

ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ ២៥៧/២៣ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០២៣
ស្តីពីការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ
និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ

## តារាងកម្មវិធីទទួលបានប្រាក់ឧបត្ថម្ភករណីកូនរលូត កូនស្លាប់ពេលសម្រាល និងម្តាយស្លាប់ក្នុងពេលសម្រាល

| ដំណាក់កាល | ចំនួនលើក | ពេលវេលាទៅពិនិត្យសុខភាព |
|---|---|---|
| **ពិនិត្យផ្ទៃពោះ** | ពិនិត្យផ្ទៃពោះលើកទី១គភ៌រលូត | មានគភ៌អាយុតិចជាង១២សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះរួចគភ៌រលូត | គភ៌អាយុ១២សប្តាហ៍ក្រោម២៤សប្តាហ៍ |
| | ក្រោយរលូតពិនិត្យសុខភាពលើកទី២ | តាមការកំណត់របស់ពេទ្យជាលើកទី២ (ចុងក្រោយ) |
| **កូនស្លាប់ពេលសម្រាល** | កូនស្លាប់ពេលសម្រាល | តាមភាពជាក់ស្តែង |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី១ | តាមការកំណត់របស់ពេទ្យ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី២ | តាមការកំណត់របស់ពេទ្យ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៣ | តាមការកំណត់របស់ពេទ្យ(ផ្តល់ជូនជាលើកចុងក្រោយ) |
| **ម្តាយស្លាប់ពេលសម្រាល** | ពិនិត្យសុខភាពកូនលើកទី១ | ថ្ងៃទី៧ក្រោយសម្រាល |
| | ពិនិត្យសុខភាពកូនលើកទី២ | ថ្ងៃទី១៤ក្រោយសម្រាល |
| | ពិនិត្យសុខភាពកូនលើកទី៣ | កូនមានអាយុ១ខែកន្លះ |
| | ពិនិត្យសុខភាពកូនលើកទី៤ | កូនមានអាយុ២ខែកន្លះ |
| | ពិនិត្យសុខភាពកូនលើកទី៥ | កូនមានអាយុ៣ខែកន្លះ |
| | ពិនិត្យសុខភាពកូនលើកទី៦ | កូនមានអាយុ៦ខែ |
| | ពិនិត្យសុខភាពកូនលើកទី៧ | កូនមានអាយុ៩ខែ |
| | ពិនិត្យសុខភាពកូនលើកទី៨ | កូនមានអាយុ១២ខែ |
| | ពិនិត្យសុខភាពកូនលើកទី៩ | កូនមានអាយុ១៨ខែ |
| | ពិនិត្យសុខភាពកូនលើកទី១០(ចុងក្រោយ) | កូនមានអាយុ២៤ខែ |